# ការពិភាក្សាផ្លាស់ប្តូរយោបល់រវាងសង្គមស៊ីវិល និងភ្នាក់ងារអនុវត្ត ទាក់ទងនឹងការទទួលបានសេវាកម្មយុត្តិធម៌ ឆ្នាំ២០០៩

## ខេត្តបន្ទាយមានជ័យ កំពង់ធំ កំពង់ចាម និងខេត្តព្រៃវែង

អគ្គលេខាធិការដ្ឋាន

ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

## ១. សេចក្តីផ្តើម៖

ក្នុងអំឡុងពេលខែកញ្ញា និងខែតុលា ឆ្នាំ២០០៩ អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ចាប់រៀបចំសិក្ខាសាលាមួយចំនួន ដើម្បីលើកស្ទួយការពិភាក្សាពិគ្រោះយោបល់រវាងភ្នាក់ងារអនុវត្តរបស់រាជរដ្ឋាភិបាល ជាមួយនឹងសង្គមស៊ីវិល លើបញ្ហានៃការផ្តល់ និងការទទួលបានសេវាកម្មយុត្តិធម៌ ។ សិក្ខាសាលាត្រូវបានរៀបចំឡើងនៅខេត្តបន្ទាយមានជ័យ កំពង់ធំ កំពង់ចាម និងខេត្តព្រៃវែង ហើយទទួលបានការឧបត្ថម្ភថវិកាដោយទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិដាណឺម៉ាក (DANIDA) និងមានជំនួយបច្ចេកទេសពីទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិរបស់អូស្ត្រាលី ( AusAID) ។ សិក្ខាសាលាក្នុងខេត្តនីមួយៗមានសិក្ខាកាមចូលរួមប្រមាណ ១៥០នាក់ រួមមានក្រុមប្រឹក្សាឃុំ/សង្កាត់ អភិបាល/អភិបាលរងស្រុក សង្គមស៊ីវិល ផ្នែកឯកជន នគរបាលប៉ុស្តិ៍និងអធិការ/អធិការរងស្រុក មន្ត្រីពន្ធនាគារខេត្ត កងរាជអាវុធហត្ថ មន្ទីរជុំវិញខេត្ត និងចៅក្រម ព្រះរាជអាជ្ញា និងក្រឡាបញ្ជី ។

អ្នកចូលរួមទាំងអស់ត្រូវបានផ្តល់ជូននូវកញ្ចប់ឯកសារ ដែលរួមមានមគ្គុទ្ទេសក៍នៃការធ្វើផែនការសម្រាប់ស្ថាប័នក្នុងវិស័យយុត្តិធម៌ ផែនការសកម្មភាពអនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការ យុទ្ធ-សាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការ ប្រព័ន្ធសូចនាករតាមដានការអនុវត្តន៍យុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការ បញ្ជីគម្រោងកំណែទម្រង់ច្បាប់ និងតុលាការ ឯកសារចក្ខុវិស័យកំណែទម្រង់ច្បាប់ និងតុលាការ ឯកសារស្តីពីភាពជឿនលឿននៃការអនុវត្តន៍ផែនការសកម្មភាពកំណែទម្រង់ច្បាប់ និងតុលាការ ព្រឹត្តិបត្រកំណែទម្រង់ច្បាប់ និងតុលាការ និងឯកសារតុលាការគំរូ ។ សម្រាប់អ្នកចូលរួមភាគច្រើន នេះគឺជាលើកទី១ហើយដែលខ្លួនបាននូវឯកសារបែបនេះ ។

សិក្ខាសាលាក្នុងខេត្តនីមួយៗមានរយៈពេលមួយថ្ងៃកន្លះ ។ ថ្ងៃទី១រួមមានការបង្ហាញអំពីកំណែទម្រង់ច្បាប់ និងតុលាការ ដោយអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងសុន្ទរកថាដោយអភិបាលខេត្តរង ។ បទបង្ហាញអំពីនីតិវិធីរដ្ឋប្បវេណីនិងព្រហ្មទណ្ឌ ដោយប្រធានតុលាការ និងអយ្យការ ។ បន្ទាប់មកតំណាងអង្គការសង្គមស៊ីវិលធ្វើបទបង្ហាញអំពីបញ្ហាការទទួលសេវាកម្មយុត្តិធម៌នៅក្នុងខេត្ត ហើយនគរបាលក៏មានបទអន្តរាគមន៍ផងដែរ ។ បន្ទាប់ពីបទបង្ហាញទាំងនេះ ក៏មានទុកពេលវេលាសម្រាប់ការសួរឆ្លើយផងដែរ ។

ជាការកត់សំគាល់ គឺតុលាការដែលបានចូលរួមក្នុងដំណើរការតុលាការគំរូ មានការយល់ដឹងច្រើននៅពេលឆ្លើយសំណួរនានាពីបណ្តាអ្នកចូលរួម ។ តុលាការទាំងនេះជានិច្ចកាលមានការយល់ដឹងបានច្រើនអំពីបញ្ហានៃការប្រឈម និងគោលការណ៍ដែលត្រូវអនុវត្ត ។ ជាលទ្ធផលនោះគឺថាតុលាការទាំងនេះអាចចូលរួមក្នុងការ ជជែកពិភាក្សាប្រកប ដោយន័យស្ថាបនា ហើយជាទូទៅមានការទទួលយកនូវបញ្ហាដែលបានចោទឡើងនៅក្នុងប្រព័ន្ធ ។ តុលាការគំរូមានវិធីសាស្រ្តដើម្បីដោះស្រាយបញ្ហាតាមរយៈរចនាសម្ព័ន្ធដែលបានកំណត់នៅក្នុងផែនការយុទ្ធសាស្រ្តរបស់ខ្លួន ។

នៅថ្ងៃទី២ សិក្ខាកាមត្រូវបានបែងចែកចេញជាក្រុម ដើម្បីពិភាក្សាលើបញ្ហាការប្រឈមចំពោះការទទួល និងការផ្តល់សេវាយុត្តិធម៌ ព្រមទាំងមានការផ្តល់អនុសាសន៍របស់ក្រុមផងដែរ ដើម្បីធ្វើយ៉ាងណាឱ្យប្រព័ន្ធយុត្តិធម៌មានភាពកាន់តែល្អប្រសើរឡើង ។ ក្រុមនីមួយៗឡើងបង្ហាញជូនអង្គសិក្ខាសាលាអំពីលទ្ធផលនៃការពិភាក្សារបស់ពួកគេ ។

សិក្ខាសាលាបានផ្តល់ឱកាសឱ្យមានការលើកឡើងអំពីបញ្ហាដែលកើតឡើងនៅថ្នាក់ឃុំ និងផ្តល់ឱកាសផងដែរដល់សង្គមស៊ីវិលអាចចូលរួមផ្តល់មតិយោបល់ប្រកបដោយន័យស្ថាបនា លើបញ្ហាទាំងឡាយដែលត្រូវបានមើលឃើញជាទូទៅថាជាប្រធានបទរសើប ។ ការសម្របសម្រួលរវាងថ្នាក់ដឹកនាំខេត្ត និងអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ធានាបាននូវបរិយាកាសត្រឹមត្រូវសម្រាប់ការពិភាក្សាបែបនេះធ្វើឡើងប្រកបដោយន័យស្ថាបនា ។

## ២. សង្ខេបលទ្ធផលសិក្ខាសាលា

### ២.១ បញ្ហាប្រឈមចំពោះការទទួល និងការផ្តល់សេវាកម្មយុត្តិធម៌

ទោះបីជាអ្នកចូលរួមមកពីក្រុមផ្សេងៗគ្នាក៏ដោយ ក៏ពួកគេយល់ឃើញស្របគ្នាចំពោះប្រភេទនៃបញ្ហាប្រឈមសំខាន់ៗទាំងឡាយ ។

បញ្ហាប្រឈមដែលសំខាន់បំផុតនោះគឺកង្វះព័ត៌មានសម្រាប់ប្រជាពលរដ្ឋ និងអ្នកអនុវត្តច្បាប់ ជាពិសេសនៅថ្នាក់ឃុំ/សង្កាត់ រួមទាំងព័ត៌មានអំពីច្បាប់ដែលទើបចេញថ្មី និងនីតិវិធីទាំងឡាយសម្រាប់ការទទួលបានសេវាកម្មយុត្តិធម៌ ។ សិក្ខាកាមយល់ថា បញ្ហានៃការមិនគោរពច្បាប់ បញ្ហាអនុវត្តច្បាប់និងបញ្ហាជំនឿ

ទុកចិត្តលើប្រព័ន្ធយុត្តិធម៌ គឺបណ្តាលមកពីកង្វះព័ត៌មានជាមូលដ្ឋាន និងការមិនទាន់យល់ច្បាស់នៅថ្នាក់ឃុំ/សង្កាត់ ។ ពួកគាត់យល់ឃើញថា បញ្ហាទាំងនេះបានជំរុញឱ្យមន្ត្រីថ្នាក់មូលដ្ឋាន និងមន្ត្រីអនុវត្តច្បាប់ ទាំងឡាយនៅថ្នាក់ឃុំ/សង្កាត់ ស្វែងរកមធ្យោបាយក្រៅផ្លូវការក្នុងការដោះស្រាយបញ្ហាយុត្តិធម៌ ដែលនាំឱ្យពួកគាត់មានបញ្ហាខ្វាស់ជាមួយច្បាប់ និងបដិសេធនូវសិទ្ធិដែលគេត្រូវទទួលបានតាមច្បាប់ ។ ផ្ទុយមកវិញ វាបានធ្វើឱ្យមានការភាន់ច្រឡំនៅថ្នាក់ឃុំ/សង្កាត់ ចំពោះបញ្ហាទំនាក់ទំនងរវាងយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ និងក្នុងតុលាការ ។



សិក្ខាកាមក៏បានកត់សំគាល់ឃើញផងដែរ បញ្ហាកង្វះធនធានសម្រាប់វិស័យយុត្តិធម៌ នាំឱ្យបន្ថយលទ្ធភាពនៃការផ្តល់សេវាយុត្តិធម៌ឱ្យមានប្រសិទ្ធភាព ។ ជាពិសេសគឺបញ្ហាដែលច្រើនតែកើតឡើងនៅបណ្តាឃុំដាច់ស្រយាល ដែលមានការលំបាកក្នុងការរកសោហ៊ុយធ្វើដំណើរក្នុងការងារស៊ើបអង្កេត ហើយការធ្វើដំណើរមកកាន់តុលាការនៅខេត្តក៏ត្រូវចំណាយច្រើនផងដែរ ។ បញ្ហានេះមិនមែនមានសម្រាប់តែមន្ត្រីនគរបាលយុត្តិធម៌ប៉ុណ្ណោះទេ ប៉ុន្តែក៏ជាបញ្ហាសម្រាប់មន្ត្រីតុលាការ និងពន្ធនាគារផងដែរ ។ សិក្ខាកាមដែលបានចូលរួមយល់ឃើញជាទូទៅថា គួរតែមានការផ្តល់ធនធានបន្ថែមដល់វិស័យយុត្តិធម៌ ដើម្បីពន្លឿនដំណើរការ និងពង្រីកទីតាំងភូមិសាស្ត្រនៃប្រព័ន្ធយុត្តិធម៌ផ្លូវការ ។

បញ្ហាសីលធម៌មន្ត្រីដែលបំរើសេវាសាធារណៈក៏ត្រូវបានកត់សំគាល់ឃើញថាជាបញ្ហាប្រឈមជាគន្លឹះផងដែរ ។ សូមកត់សំគាល់ថា បញ្ហាសីលធម៌វាខុសគ្នាពីបញ្ហាអំពើពុករលួយ ។ សិក្ខាកាមដែលបានចូលរួមមានការកត់សំគាល់ឃើញថា មន្ត្រីជាច្រើនមិនបានចេញមកជួបតាមពេលម៉ោងដែលខ្លួនបានណាត់ ហើយមានការយឺតយ៉ាវក្នុងការស៊ើបអង្កេត ហើយជាទូទៅមិនយកចិត្តទុកដាក់ពីបញ្ហាបន្ទាន់ទាក់ទងនឹងការដោះស្រាយបណ្តឹងជូនប្រជាពលរដ្ឋ ។ បញ្ហានេះធ្វើឱ្យប្រជាពលរដ្ឋលែងចង់ប្រើសេវាយុត្តិធម៌ផ្លូវការ ហើយក៏ជាកត្តារួមចំណែកចំពោះកង្វះការជឿទុកចិត្តរបស់ប្រជាពលរដ្ឋនៅក្នុងប្រព័ន្ធយុត្តិធម៌ផ្លូវការនេះដែរ ។

## ២.២ អនុសាសន៍ចំពោះការផ្តល់និងការទទួលសេវាកម្មយុត្តិធម៌

បញ្ហាកង្វះព័ត៌មាន ជាពិសេសនៅថ្នាក់ឃុំ/សង្កាត់ គឺជាបញ្ហាប្រឈមនៃការផ្តល់ និងការទទួលសេវាកម្មយុត្តិធម៌ ហើយសិក្ខាកាមដែលបានចូលរួមបានផ្តល់ជាអនុសាសន៍ឱ្យមានការបណ្តុះបណ្តាលបន្ថែមដល់មន្ត្រីនៅមូលដ្ឋាន ហើយសុំឱ្យមានការផ្សព្វផ្សាយច្បាប់ឱ្យបានទូលំទូលាយដល់ប្រជាពលរដ្ឋទូទៅ ដើម្បីឱ្យការកែទម្រង់មានប្រសិទ្ធភាព ។ នេះគិតរួមទាំងព័ត៌មានស្តីពីនីតិវិធី និងទម្រង់បែបបទ ព្រមទាំងឯកសារផ្សេងៗដែលត្រូវការចាំបាច់នៅក្នុងប្រព័ន្ធយុត្តិធម៌ផ្លូវការ ។




សិក្ខាកាមយល់ឃើញថា គួរតែមានវិធានការស្មើភាពគ្នាក្នុងការត្រួតពិនិត្យតាមដាន និងគួរមានយន្តការដាក់វិន័យ ដើម្បីធ្វើឱ្យប្រសើរឡើងនូវបទដ្ឋានក្រមសីលធមិសម្រាប់មន្ត្រីតុលាការ នគរបាលយុត្តិធមិ និងមន្ត្រីផ្សេងៗទៀត ក្នុងវិស័យយុត្តិធមិ ដើម្បីបង្កើនជំនឿទុកចិត្តក្នុងប្រព័ន្ធ និងកាត់បន្ថយអំពើពុករលួយ។ នេះគឺជាអនុសាសន៍មួយដ៏សំខាន់ ដោយសារតែសិក្ខាកាមខ្លួនឯងភាគច្រើនគឺជាមន្ត្រីបំរើការក្នុងវិស័យយុត្តិធមិ។ អនុសាសន៍នេះខុសប្លែកពីអនុសាសន៍ស្តីពីក្រមសីលធមិវិជ្ជាជីវៈរបស់មន្ត្រីអនុវត្តច្បាប់ ដែលសិក្ខាកាមយល់ថាមានសារៈសំខាន់ ប៉ុន្តែមិនសំខាន់ដូចអនុសាសន៍នេះឡើយ។

សិក្ខាកាមក៏មើលឃើញផងដែរនូវបញ្ហាកង្វះធនធាន ដែលកាត់បន្ថយលទ្ធភាពរបស់ស្ថាប័នក្នុងវិស័យនេះក្នុងបំពេញតួនាទីនិងភារកិច្ចរបស់ខ្លួន។ ហេតុនេះហើយទើបមានអនុសាសន៍ស្នើសុំឱ្យមានការបង្កើនធនធានបន្ថែមសម្រាប់វិស័យយុត្តិធមិ ដែលរួមមានការសុំបង្កើនធនធានហិរញ្ញវត្ថុ បន្ថែមបុគ្គលិកសម្រាប់ទាំងនគរបាលយុត្តិធមិ ទាំងតុលាការ ព្រមទាំងស្នើសុំឱ្យមានឧបករណ៍សម្ភារៈ និងមធ្យោបាយសម្រាប់ការ

ស៊ើបអង្កេត ។ សម្រាប់អ្នកមកពីតំបន់ដាច់ស្រយាល ក៏បានសង្កត់បញ្ជាក់បន្ថែមផងដែរថា ជាទូទៅប្រជាពលរដ្ឋគ្មានធនធានគ្រប់គ្រាន់ ក្នុងការធ្វើដំណើរមកកាន់តុលាការនៅខេត្តឡើយ ហេតុនេះពួកគេ មិនអាចប្រើប្រាស់សេវាយុត្តិធម៌ផ្លូវការឡើយ លុះត្រាតែពេលណាដែលគេមានធនធានគ្រប់គ្រាន់ បើពុំដូច្នោះទេ ពួកគេនៅតែមិនអាចប្រើសេវាយុត្តិធម៌ផ្លូវបានឡើយ វៀរលែងតែក្នុងករណីមានបទឧក្រិដ្ឋធ្ងន់ធ្ងរ និង រឿងរដ្ឋប្បវេណីភាគច្រើន ។

## ៣. លទ្ធផលនៃសិក្ខាសាលា

*(i) បង្កើនការយល់ដឹងអំពីច្បាប់ និងនីតិវិធី*

សិក្ខាកាមភាគច្រើនផ្តល់យោបល់ថា នេះជាលើកទីមួយហើយដែលគេបានទទួលព័ត៌មានយ៉ាងទូលំទូលាយ អំពីនីតិវិធីរដ្ឋប្បវេណី និងនីតិវិធីព្រហ្មទណ្ឌថ្មី ព្រមទាំងព័ត៌មានអំពីច្បាប់ថ្មីៗ រួមទាំងព័ត៌មានអំពីនីតិវិធីផ្សេងៗទៀត ដែលទាក់ទងនឹងការទទួលបានយុត្តិធម៌តាមរយៈតុលាការ ។ ក្នុងនោះរួមមានទាំងការបកស្រាយអំពីតួនាទីនៃយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ក្នុងសេវាកម្មយុត្តិធម៌ និងទំនាក់ទំនងសេវាកម្មនេះជាមួយនឹងរចនាសម្ព័ន្ធផ្លូវការរបស់តុលាការ ។

*(ii) ឱកាសចែករំលែកមតិយោបល់ដោយន័យស្ថាបនា*

សិក្ខាកាមភាគច្រើនយល់ឃើញថា វេទិកានេះផ្តល់ឱកាសដល់ពួកគេក្នុងការផ្តល់មតិយោបល់ដោយន័យស្ថាបនាជាមួយអ្នកពាក់ព័ន្ធផ្សេងៗដែលជាគូបដិបក្ខ ។ ក្នុងនោះរួមមានទាំងផ្នែកសង្គមស៊ីវិល នគរបាលយុត្តិធម៌ តុលាការ ពន្ធនាគារ ក្រុមប្រឹក្សាឃុំ/សង្កាត់ និងមន្ត្រីខេត្តនិងស្រុក ។ ក្រុមនីមួយៗមានការទទួលខុសត្រូវ និងមានបញ្ហាប្រឈមផ្សេងៗគ្នា ហើយវេទិកានេះផ្តល់ឱកាសឱ្យគេអាចលើកឡើងនូវបញ្ហាទាំងឡាយដែលមានពីការខុសឆ្គងផ្ទាល់ខ្លួន និងស្ថាប័ន ដោយមិនមានឆ្លើយដោះសារការពារខ្លួននោះឡើយ ។ លទ្ធផលចុងក្រោយនោះគឺការពិភាក្សាដោះដូរយោបល់ប្រកបដោយន័យស្ថាបនា ព្រមទាំងមានការយល់ដឹងថ្មីៗបន្ថែមទៀតទាក់ទងនឹងកាតព្វកិច្ច និងបញ្ហាប្រឈមរបស់អ្នកពាក់ព័ន្ធផ្សេងៗ ព្រមទាំងកំណត់អំពីកាតព្វកិច្ច និងបញ្ហាប្រឈមដែលភាគីនានាមានជារួម ។

*(iii) បានយល់ដឹងអំពីកំណែទម្រង់ច្បាប់ និងតុលាការកាន់តែច្រើន*

សិក្ខាកាមខ្លះក៏បានផ្តល់យោបល់របស់គេអំពីការយល់ដឹងកាន់តែច្រើនអំពីគោលនយោបាយរបស់រាជរដ្ឋាភិបាល និងអំពីកំណែទម្រង់នានារបស់រាជរដ្ឋាភិបាលផងដែរ ។ ការមានយោបល់បែបនេះត្រូវបានលើកឡើងជាពិសេសដោយសិក្ខាកាមមកពីបណ្តាឃុំដែលពុំសូវមានព័ត៌មានបែបនេះទៅដល់ ។ គេយល់ឃើញ

ថាឯកសារដែលបានចែកជូននឹងជាទុនសម្រាប់សិក្ខាកាមក្នុងការផ្សព្វផ្សាយបន្តអំពីព័ត៌មានដែលគេទទួលបាននេះ ។

*(iv) ពង្រឹងសមត្ថភាពសម្របសម្រួលរបស់អគ្គលេខាធិការដ្ឋាន*

សិក្ខាសាលាបានផ្តល់នូវទំនាក់ទំនង និងវិធីសាស្ត្រថ្មី សម្រាប់ការចូលរួមរបស់អ្នកពាក់ព័ន្ធនៅក្នុងកំណែ-ទម្រង់ច្បាប់ និងតុលាការ ។ ពេលនេះអគ្គលេខាធិការដ្ឋានមានទម្រង់មួយទៀតដែលបានអនុវត្តប្រកបដោយជោគជ័យ ហើយអាចយកទៅប្រើប្រាស់នៅកន្លែងផ្សេងទៀត ដើម្បីធ្វើឱ្យប្រសើរឡើងនូវសមត្ថ-ភាពក្នុងនាមជាអ្នកសម្របសម្រួលការអនុវត្តន៍កំណែទម្រង់ច្បាប់ និងតុលាការជារួម ។

*(v) វេទិកាសម្រាប់សង្គមស៊ីវិលចូលរួមក្នុងកំណែទម្រង់ច្បាប់ និងតុលាការ*

អ្នកចូលរួមចំរុះមានចំនួនច្រើនក្នុងវេទិកាអនុញ្ញាតឱ្យសង្គមស៊ីវិល និងផ្នែកឯកជនអាចផ្តល់មតិយោបល់របស់ខ្លួនប្រកបដោយន័យស្ថាបនាលើការអនុវត្តន៍កំណែទម្រង់ ហើយផ្តល់អនុសាសន៍នានាទាក់ទងនឹងផ្នែកបច្ចេកទេស ដោយក៏រិតកំណត់នៃការតស៊ូមតិពីភាគីទាំងសងខាង ។

*(vi) ការមតិយោបល់ទាក់ទងនឹងឧបសគ្គចំពោះការអនុវត្តន៍កំណែទម្រង់ និងអនុសាសន៍កែលំអ*

សិក្ខាសាលានេះផ្តល់ជាទីកន្លែងមួយសម្រាប់អ្នកធ្វើការនៅសហគមន៍មូលដ្ឋាន អាចលើកឡើងអំពីបញ្ហានានាដែលជាឧបសគ្គចំពោះពួកគេ និងធានាពាំនាំអនុសាសន៍នានារបស់ពួកគេមកកាន់ថ្នាក់លើដែលជាអ្នករៀបចំគោលនយោបាយ ។ នេះជាចំណុចសំខាន់មួយ ព្រោះថាលំហូរនៃព័ត៌មានពីអ្នកតាក់តែងគោលនយោបាយនៅភ្នំពេញ និងអ្នកអនុវត្តនៅមូលដ្ឋានតែងតែមានបញ្ហាដោយសារមូលហេតុផ្សេងៗ ។ សិក្ខាសាលាផ្តល់ឱកាសឱ្យមានការពិភាក្សាគ្នា ហើយព័ត៌មានដែលទទួលបានដោយអ្នកធ្វើសេចក្តីសម្រេចចិត្ត និងអ្នកអនុវត្តជាក់ស្តែងអាចនឹងជួយដល់ការធ្វើឱ្យប្រសើរឡើងនូវការអនុវត្តន៍កំណែទម្រង់ច្បាប់ និងតុលាការ ។

## ៤. បទពិសោធន៍ដែលទទួលបាន

*(i) ការប្រើប្រាស់ទីកន្លែងអព្យាក្រឹត*

សិក្ខាសាលាត្រូវបានរៀបចំឡើងនៅសណ្ឋាគារនៅខេត្តបី ហើយខេត្តមួយទៀតធ្វើនៅសាកលវិទ្យាល័យ ។ ការប្រើទីកន្លែងអព្យាក្រឹតបានផ្តល់ប្រយោជន៍ច្រើន ព្រោះបានជំរុញឱ្យមានការចូលរួមយ៉ាងសកម្មពីសំណាក់តុលាការ និងសង្គមស៊ីវិល ហើយបានកាត់បន្ថយអារម្មណ៍ដែលយល់ថាសិក្ខាសាលាត្រូវបានបង្គាប់បញ្ជាដោយនីតិប្រតិបត្តិ ។

*(ii) វចនាសម្ព័ន្ធសិក្ខាសាលា*

សិក្ខាសាលាត្រូវការពេលវេលាបន្ថែមសម្រាប់ការពិភាក្សាអំពីនីតិវិធី ។ សិក្ខាកាមភាគច្រើនបញ្ជាក់ថានេះជាលើកដំបូងហើយ ដែលគេមានឱកាសលើកឡើងនូវសំណួរទាក់ទងនឹងនីតិវិធី ជាមួយតុលាការ និងអយ្យការ ហើយវាទាមទារនូវពេលវេលាខ្លះផងដែរ ។ សិក្ខាកាមយល់ឃើញថា ការពិគ្រោះយោបល់ទាំងនេះមានលក្ខណៈជាការអប់រំ ហើយជាទូទៅដោះស្រាយលើបញ្ហាដែលកើតមានឡើងជាក់ស្តែង ដែលកើតមាននៅក្នុងសហគមន៍របស់គេ ។

*(iii) តម្រូវការព័ត៌មាន*

ឯកសារជាច្រើនត្រូវបានចែកជូនដល់សិក្ខាកាម ហើយការចំណាយលើការបោះពុម្ពច្រើនជាងពាក់កណ្តាលនៃថវិកាទាំងអស់សម្រាប់សិក្ខាសាលា ។ សូម្បីមានការបោះពុម្ពយ៉ាងច្រើនដូច្នេះក៏ដោយ ក៏នៅមានតម្រូវការសុំឯកសារបន្ថែម ហើយការបោះពុម្ពបន្ថែមក៏ត្រូវបានធ្វើឡើង ។ សម្រាប់សិក្ខាសាលានៅពេលខាងមុខ គេគួរតែពិចារណាឆ្លៀតឱកាសនេះ ដើម្បីផ្សព្វផ្សាយព័ត៌មានទៅតាមខេត្តនានា រួមទាំងស្រុក/ក្រុង និងឃុំ/សង្កាត់មួយចំនួនផងដែរ ។ ដើម្បីបំពេញតម្រូវការនេះ គេគួរតែរៀបចំឱ្យមានច្បាប់ និងនីតិវិធីថ្មីៗ ដែលពាក់ព័ន្ធដើម្បីផ្សព្វផ្សាយផងដែរ ។

*(iv) អគ្គលេខាធិការដ្ឋាន*

អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌គឺជាអ្នកសម្របសម្រួលដ៏ល្អ និងមានសារៈសំខាន់ ព្រោះបានដើរតួនាទីដែលទទួលបានការជឿទុកចិត្តពីសំណាក់អង្គតុលាការ និងអង្គនីតិប្រតិបត្តិ ។ ជាលទ្ធផលទំនាក់ទំនងជាមួយក្រុមអង្គការសង្គមស៊ីវិលនៅតាមខេត្តក៏មានលក្ខណៈល្អប្រសើរឡើងផងដែរ ។

*(v) ការចូលរួមពីផ្នែកឯកជន*

ការចូលរួមរបស់ផ្នែកឯកជននៅក្នុងការពិភាក្សា និងការផ្តល់យោបល់មានសារៈសំខាន់ ហើយត្រូវបានបង្ហាញថាមានប្រយោជន៍នៅខេត្តបន្ទាយមានជ័យ ។ ការចូលរួមរបស់ផ្នែកឯកជននៅខេត្តផ្សេងទៀតមិនសូវទទួលបានជោគជ័យឡើយ ។ បញ្ហាអាចមកពីអ្នកសម្របសម្រួល ការជួយរបស់ដៃគូអភិវឌ្ឍន៍ និងអាជ្ញាធរខេត្តពុំសូវមានបទពិសោធន៍ក្នុងការងារទំនាក់ទំនងជាមួយផ្នែកឯកជន ។ គេគួរតែបន្តខិតខំប្រឹងប្រែងឱ្យមានការចូលរួមពីផ្នែកឯកជន ហើយគួរមានការពិភាក្សាឱ្យបានច្រើនថែមទៀតជាមួយសភាពាណិជ្ជកម្មនៅតាមខេត្តនីមួយៗ ។

## ៥. អនុសាសន៍

បន្ទាប់ពីបានបញ្ចប់សិក្ខាសាលានៅខេត្តទាំង៤រួចមក និងបន្ទាប់ពីការវិភាគព័ត៌មានដែលទទួលបានពីអ្នកចូលរួមមក អនុសាសន៍មួយចំនួនត្រូវបានលើកឡើងៈ

(i) គួររៀបចំសិក្ខាសាលាបែបនេះបន្ថែមនៅផ្សេងៗទៀត

(ii) ព័ត៌មានដែលទទួលបានគួរយកធ្វើជាមូលដ្ឋានសម្រាប់ប្រព័ន្ធសូចនាករតាមដាន (IMS)

(iii) គួរមានផែនការសម្រាប់ការធ្វើឱ្យប្រសើរឡើងនូវការផ្សព្វផ្សាយព័ត៌មានអំពីច្បាប់ និងនីតិវិធីដល់សហគមន៍មូលដ្ឋានឱ្យបានទូទាំងប្រទេស

(iv) អនុសាសន៍ដែលលើកឡើងដោយសិក្ខាកាមគួរដាក់ជូនក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ដើម្បីពិចារណា

**ឧបសម្ព័ន្ធទី១៖ ក្រុមពិភាក្សា**

***សង្ខេបលទ្ធផល និងអនុសាសន៍ (បន្ទាយមានជ័យ កំពង់ធំ កំពង់ចាម និងព្រៃវែង)***

| **ក្រុមប្រឹក្សាឃុំ/សង្កាត់៖**<br>**បញ្ហាប្រឈម៖** | **អនុសាសន៍៖** |
| --- | --- |
| ● ខ្វះការយល់ដឹងពីច្បាប់ ហើយខ្វះព័ត៌មានទៅដល់ឃុំ/សង្កាត់ រួមទាំងមន្ត្រីអនុវត្តច្បាប់ផង។ នាំឱ្យមានការលំបាកក្នុងការកំណត់ថាអ្វីទៅជាបទល្មើស ហើយអ្វីមិនមែនជាបទល្មើស។<br>● ប្រជាពលរដ្ឋភាគច្រើនមិនដឹងអំពីនីតិវិធីនៃការដាក់ពាក្យបណ្ដឹង ហើយគ្មានព័ត៌មានគ្រប់គ្រាន់ដើម្បីជួយដល់ពួកគេ។<br>● ប្រជាពលរដ្ឋភាគច្រើនចង់ដោះស្រាយបណ្ដឹងនៅត្រឹមថ្នាក់ឃុំ/សង្កាត់។ ក្រុមប្រឹក្សាឃុំនៅមិនទាន់យល់ច្បាស់អំពីអ្វីដែលខ្លួនអាចដោះស្រាយបាន ហើយអ្វីដោះស្រាយមិនបាន។<br>● ពលរដ្ឋក្រីក្រមិនអាចរកមេធាវី និងមិនអាចចូលទៅតុលាការបាន។ នេះគឺជាការលំបាកមួយ ជាពិសេសនៅពេលដោះស្រាយរឿងក្តីមានការយឺតយ៉ាវ។<br>● ដីកា និងការជូនដំណឹងពីតុលាការប្រគល់មកឃុំមិនគ្រប់គ្រាន់ យឺតពេល ឬជូនកាលដើមបណ្ដឹងយកមកដោយខ្លួនឯង។<br>● មានអ្នកគួកជេរសំណុំរឿង នាំឱ្យប៉ះពាល់ដល់ដំណើរការយុត្តិធម៌ ហើយកើតឡើងដោយគ្មានការទប់ស្កាត់។ | ● គួរមានការផ្សព្វផ្សាយព័ត៌មានអំពីច្បាប់ និងនីតិវិធីដល់ថ្នាក់ឃុំ/សង្កាត់អំពីការចុះបញ្ជីបណ្ដឹង ដោយរួមមានទាំងការបង្កើតវគ្គបណ្ដុះបណ្ដាលសម្រាប់ក្រុមប្រឹក្សាឃុំ/សង្កាត់។<br>● គួរកាត់បន្ថយពន្ធប្រដាប់ក្តី និងពន្ធផ្សេងៗទៀត ដើម្បីឱ្យអ្នកក្រីក្រអាចមានលទ្ធភាពក្នុងក្នុងការប្រើសេវាកម្មយុត្តិធម៌។<br>● ការសម្របសម្រួលធ្វើឡើងដោយក្រុមប្រឹក្សាឃុំ/សង្កាត់ គួរតុលាការយកមកពិចារណាផង។<br>● សំណូមពរឱ្យមានការដោះស្រាយបណ្ដឹងឱ្យបានឆាប់រហ័ស ហើយការជូនដំណឹងផ្សេងៗគួរមានចុះពេលវេលាឱ្យបានច្បាស់លាស់។ |
| | |

| | |
|---|---|
| **អភិបាល និងអភិបាលរងស្រុក**<br>**បញ្ហាប្រឈមៈ**<br>• ខ្វះការយល់ដឹងអំពីច្បាប់ រួមទាំងមន្ត្រីអនុវត្តច្បាប់ផង ហើយការផ្សព្វផ្សាយ មានតិចតួចនៅថ្នាក់ស្រុក ។<br>• ភាគីបណ្ដឹងខ្លះប្រើការទំនាក់ទំនង ឬការសូកប៉ាន់ដើម្បីឈ្នះក្ដី។ មានសេចក្ដីសំរេចរដ្ឋបាលខ្លះផ្ទុយពីសេចក្ដីសំរេចរបស់តុលាការ ហើយបង្កឱ្យមានការភាន់ច្រឡំ។<br>• កង្វះសីលធម៌ និងការយល់ដឹង នាំឱ្យបន្ថយនូវការជឿទុកចិត្តរបស់ប្រជាពលរដ្ឋមកលើមន្ត្រីអនុវត្តច្បាប់ និងតុលាការ។<br>• ភាពក្រីក្រដាក់កំហិតចំពោះការទទួលបានសេវាកម្មយុត្តិធម៌ និងតំណាងផ្នែកច្បាប់។<br>• ការប្រគល់ដីកា និងសេចក្ដីជូនដំណឹងធ្វើឡើងដោយភាគីទីបី ដែលមិនមែនជាមន្ត្រីតុលាការ។ | **អនុសាសន៍ៈ**<br>• គួរមានវគ្គបណ្ដុះបណ្ដាល និងការផ្សព្វផ្សាយអំពីច្បាប់ និងនីតិវិធីឱ្យបានដល់ថ្នាក់មូលដ្ឋាន។<br>• គួរមានវគ្គបណ្ដុះបណ្ដាលអំពីនីតិវិធី និងក្រមសីលធម៌សម្រាប់មន្ត្រីអនុវត្តច្បាប់។<br>• សិទ្ធិអំណាចទាក់ទងនឹងការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការគួរចែងឱ្យបានច្បាស់លាស់។<br>• ដីកា និងការជូនដំណឹងរបស់តុលាការគួរតែត្រូវប្រគល់ដោយមន្ត្រីតុលាការ ហើយពួកគេគួរមានមធ្យោបាយគ្រប់គ្រាន់។<br>• តុលាការមិនគួរទទួលសំណូក ឬឥទ្ធិពលអ្វីឡើយ ហើយគួរតែអនុវត្តដោយឯករាជ្យ។ គួរមានការឧបត្ថម្ភគាំទ្រឱ្យមានយន្តការលើកស្ទួយឯករាជភាពរបស់តុលាការ។<br>• គួរមានការិយាល័យមេធាវីនៅជិតុលាការ។ |
| **មន្ទីរជុំវិញខេត្ត និងពន្ធនាគារ**<br>**បញ្ហាប្រឈមៈ**<br>• កង្វះការយល់ដឹងអំពីច្បាប់ ពីសំណាក់ប្រជាពលរដ្ឋ រីឯការផ្សព្វផ្សាយនៅមិនទាន់គ្រប់គ្រាន់។ ខ្វះការយល់ដឹងអំពីនីតិវិធី និងរបៀបនៃការដាក់ពាក្យបណ្ដឹង។<br>• សាលក្រមស្ថាពរជាញឹកញយត្រូវបានបញ្ជូនមកយឺតពេល ឬមិនបានបញ្ជូនមកឱ្យពន្ធនាគារ | **អនុសាសន៍ៈ**<br>• មន្ត្រីអនុវត្តត្រូវទទួលខុសត្រូវចំពោះសកម្មភាពមិនត្រឹមត្រូវរបស់ពួកគេ និងការអនុវត្តការងារយឺតយ៉ាវផងដែរ។<br>• គួរមានការបណ្ដុះបណ្ដាលអំពីច្បាប់ និងការផ្សព្វផ្សាយព័ត៌មានឱ្យបានដល់មូលដ្ឋានដោយគិតរួមទាំងការបណ្ដុះបណ្ដាលក្រម |

| | |
|---|---|
| ឡើយ ។<br>● ជាញឹកញយ ការស៊ើបអង្កេតមិនបានផ្តល់ភស្តុតាងគ្រប់គ្រាន់ ។ ភស្តុតាងមួយចំនួនគ្រាន់តែជាឯកសារដែលក្លែងបន្លំ ជាពិសេសក្នុងរឿងដីធ្លី ។<br>● ប្រជាពលរដ្ឋនៅមានការភាន់ច្រឡំអំពីតួនាទីរបស់ក្រុមប្រឹក្សាឃុំ/សង្កាត់ នគរបាល និងតុលាការនៅក្នុងការដោះស្រាយវិវាទ ។<br>● ការអនុវត្តន៍ច្បាប់មិនស្របគ្នា នាំឱ្យកាត់បន្ថយជំនឿទុកចិត្តរបស់ប្រជាពលរដ្ឋ ។<br>● ប្រជាពលរដ្ឋក្រីក្រពុំមានលទ្ធភាពរកមេធាវីការពារក្តីខ្លួនបាន ដែលនាំឱ្យខ្លួនចាញ់ក្តីក្នុងរឿងភាគច្រើន ។<br>● នៅពេលដែលអ្នកប្រព្រឹត្តខុសត្រូវបានចាប់ខ្លួនដោយភាន់ច្រឡំមកពីព័ត៌មានមិនច្បាស់លាស់ ប៉ុន្តែពេលរកឃើញការពិត គ្មាននរណាម្នាក់ទទួលខុសត្រូវចំពោះការធ្វើខុសនេះឡើយ ។ | សីលធម៌សម្រាប់មន្ត្រីអនុវត្តច្បាប់ផងដែរ ។<br>● គួរមានជំនួយផ្នែកច្បាប់ ។<br>● គួរជំរុញការដោះស្រាយវិវាទ ក្រៅប្រព័ន្ធតុលាការនៅថ្នាក់ស្រុក ។<br>● ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមគួរពង្រឹងវិធានការដាក់វិន័យលើចៅក្រម និងព្រះរាជអាជ្ញាដែលប្រព្រឹត្តកំហុសឆ្គង ។ |
| **នគរបាលប៉ុស្តិ៍ និងអធិការ/អធិការរងស្រុក**<br>**បញ្ហាប្រឈមៈ**<br>● ប្រជាពលរដ្ឋខ្វះការយល់ដឹងអំពីច្បាប់ និងនីតិវិធី ដោយគិតរួមទាំងនីតិវិធីរបស់តុលាការ ។ ការផ្សព្វផ្សាយច្បាប់ និងព័ត៌មាននៅមូលដ្ឋាននៅមានកំរិតនៅឡើយ ។<br>● ជនក្រីក្រខ្វះការជួយឧបត្ថម្ភគាំទ្រឱ្យបានគ្រប់គ្រាន់ ។<br>● កង្វះជំនឿទុកចិត្តមកលើតុលាការ ធ្វើឱ្យមាន | **អនុសាសន៍ៈ**<br>● គួរមានថវិកាដោយឡែកសម្រាប់ការបញ្ជូនដីកា និងសេចក្តីជូនដំណឹងរបស់តុលាការ ។<br>● គួរមានមធ្យោបាយសម្រាប់ការបញ្ជូនដីកាជាពិសេសទៅតំបន់ដាច់ស្រយាល ។<br>● ដីកាគួរមានរៀបរាប់ច្បាស់លាស់អំពីអត្ត-សញ្ញាណរបស់ជនដែលត្រូវទទួលដីកា ។<br>● ព្រះរាជអាជ្ញា និងតុលាការគួរប្រាប់មក |

| | |
|---|---|
| ការលំបាកក្នុងស្វែងរកសាក្សីក្នុងរឿងព្រហ្មទណ្ឌ<br>● ខ្វះការសហការគ្នារវាងតុលាការ និងមន្ទីរសុខាភិបាល ។<br>● ខ្វះរូបមន្ត នីតិវិធី និងធនធាន សម្រាប់បំរើសេវាដែលចាំបាច់ ។<br>● អង្គការក្រៅរដ្ឋាភិបាលគាំទ្រតែផ្នែកមួយចំនួនប៉ុណ្ណោះ ។<br>● ជនល្មើសខ្លះ ប្រើទំនាក់ទំនង ឬការសូកប៉ាន់ ដើម្បីបានឈ្នះក្តីនៅតុលាការ ។ | នគរបាលយុត្តិធម៌វិញ ក្នុងករណីសំណុំរឿងមិនគ្រប់គ្រាន់ ដើម្បីបំពេញបន្ថែម ។<br>● គួរមានវគ្គបណ្តុះបណ្តាលសម្រាប់មន្ត្រីអនុវត្តច្បាប់ រៀបចំឡើងដោយរដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាល ។<br>● គួរផ្តល់ឧបករណ៍បច្ចេកទេសសម្រាប់កំណត់ភស្តុតាងឱ្យបានគ្រប់គ្រាន់ ។ |
| **កងរាជអាវុធហត្ថ**<br>**បញ្ហាប្រឈម**<br>● ការយល់ដឹងអំពីច្បាប់ពីសំណាក់ប្រជាពលរដ្ឋនៅមានកំរិត ដែលជាហេតុនាំឱ្យមានឥទ្ធិពលលើការយល់ដឹងរបស់ប្រជាពលរដ្ឋ ចំពោះមូលហេតុនៃដោះលែងជនសង្ស័យខ្លះដោយ តុលាការ ។ កង្វះការយល់ដឹងអំពីនីតិវិធីក៏ជាកត្តានាំឱ្យប្រជា ពលរដ្ឋយល់ថាតុលាការពិបាក ដូច្នេះពួកគាត់មានការស្ទាក់ស្ទើរក្នុងការ ដាក់ពាក្យបណ្តឹង<br>● ជួនកាលមានអន្តរាគមន៍ពីខាងក្រៅពីប្រភពផ្សេងៗមកលើរឿងក្តី ។<br>● ការបញ្ជូនដីកា និងសេចក្តីជូនដំណឹងផ្សេងៗទៅតំបន់ដាច់ស្រយាលមានការលំបាក ដោយសារកង្វះធនធាន និងព័ត៌មានមិនគ្រប់គ្រាន់នៅក្នុងសេចក្តីជូនដំណឹង ។<br>● កិច្ចសហការមិនគ្រប់គ្រាន់រវាងនគរបាល និងកងរាជអាវុធហត្ថ ។ | **អនុសាសន៍:**<br>● បង្កើនការផ្សព្វផ្សាយច្បាប់ឱ្យដល់ជនបទ ។<br>● គួរមានថវិកាសម្រាប់បញ្ជូនដីកា និងសេចក្តីជូនដំណឹងផ្សេងៗរបស់តុលាការ ។<br>● ដីកា និងសេចក្តីជូនដំណឹងផ្សេងៗគួរផ្តល់ជូននគរបាលយុត្តិធម៌ក្នុងរយៈពេលដែលមានកំណត់ច្បាស់លាស់ ។<br>● សូមឱ្យព្រះរាជអាជ្ញា និងតុលាការទាក់ទងនគរបាលយុត្តិធម៌ ក្នុងករណីសំណុំរឿងមានភស្តុតាងមិនគ្រប់គ្រាន់ ដើម្បីរកភស្តុតាងបំពេញបន្ថែម ។<br>● គួរពង្រឹងយន្តការដើម្បីធានាឱ្យតុលាការគោរពតាមនីតិវិធីឱ្យបានត្រឹមត្រូវ ។<br>● សុំឱ្យមានឧបករណ៍បច្ចេកទេស និងនគរបាលយុត្តិធម៌បន្ថែម ។ |

| | |
|---|---|
| ● ថវិកាមិនគ្រប់គ្រាន់ ឬខ្វះឧបករណ៍ដើម្បីដំណើរការស៊ើបអង្កេតឱ្យបានត្រឹមត្រូវ ។<br>● សហគមន៍ចង់រក្សាទុកអំពើហិង្សាក្នុងគ្រួសារជាបញ្ហាផ្ទៃក្នុង ។ | |
| **សង្គមស៊ីវិល និងផ្នែកឯកជន**<br>**បញ្ហាប្រឈម**<br>● ប្រជាពលរដ្ឋខ្វះការយល់ដឹងអំពីច្បាប់ និងនីតិវិធី ដោយគិតរួមទាំងនីតិវិធីតុលាការផងដែរ ។ ការផ្សព្វផ្សាយច្បាប់ និងព័ត៌មានផ្សេងៗ តាមមូលដ្ឋាននៅមានកម្រិតនៅឡើយ ។<br>● ប្រាក់ពន្ធតុលាការច្រើនពេក ពិសេសសម្រាប់រឿងក្ដីព្រហ្មទណ្ឌ ។<br>● ប្រជាពលរដ្ឋក្រីក្រមិនអាចរកមេធាវីការពារក្ដីបាន ដែលនាំពួកគាត់ចាញ់ក្ដីភាគច្រើន ។ ការរកអ្នកតំណាងក៏មានការលំបាកផងដែរ ។<br>● នៅមានភាពមិនច្បាស់លាស់អំពីតួនាទីឃុំ/សង្កាត់ នគរបាល និងតុលាការ ក្នុងការដោះស្រាយវិវាទ រួមទាំងតួនាទីគណៈកម្មការសុរិយោដីផងដែរ ។<br>● ដំណើរការរឿងក្ដីយូរពេក នាំឱ្យបន្ថយជំនឿទុករបស់ប្រជាពរដ្ឋ ក្នុងប្រព័ន្ធយុត្តិធម៌ ។<br>● ប្រជាពរដ្ឋមិនហ៊ានធ្វើជាសាក្សី ព្រោះខ្លាចមានការសងសឹក នេះគឺដោយសារតែខ្វះការពារដល់សាក្សី និងវប្បធម៌នៃការរួចទោស ។<br>● ការសហការគ្នាមិនបានគ្រប់គ្រាន់រវាងស្ថាប័នជំនាញ និងអាជ្ញាធរផ្សេងៗ ជាមួយនឹងអង្គការ | **អនុសាសន៍ៈ**<br>● ព័ត៌មានអំពីច្បាប់ និងនីតិវិធីផ្សេងៗគួរត្រូវបានផ្សព្វផ្សាយឱ្យបានទូលំទូលាយដល់ប្រជាពលរដ្ឋ និងមន្ត្រីអនុវត្តច្បាប់ ។<br>● ក្រមសីលធម៌សម្រាប់ចៅក្រម និងព្រះរាជអាជ្ញាគួរត្រូវបានអនុវត្តឱ្យបានល្អប្រសើរថែមទៀត ។<br>● សុំឱ្យមានការអនុម័តច្បាប់ប្រឆាំងអំពើពុករលួយ ។<br>● ប្រជាពលរដ្ឋគួរត្រូវបានលើកទឹកចិត្តឱ្យពិភាក្សាអំពីបញ្ហាផ្សេងៗជាមួយមន្ត្រីអនុវត្តច្បាប់ ហើយគួរមានការដាក់វិន័យប្រឆាំងដែលប្រព្រឹត្តខុសឆ្គង ។ បញ្ហាទាំងនេះគួរឱ្យមានប្រព័ន្ធត្រួតពិនិត្យ និងតាមដាន ។<br>● ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមត្រូវចាត់វិធានការដាក់វិន័យចៅក្រម និងព្រះរាជអាជ្ញាដែលប្រព្រឹត្តខុស ។<br>● គួរបញ្ចូលមុខវិជ្ជាច្បាប់ទៅក្នុងកម្មវិធីសិក្សាសាលារៀន ។<br>● រចនាសម្ព័ន្ធផ្លូវការនៃការដោះស្រាយវិវាទ |

| | |
|---|---|
| ក្រៅរដ្ឋាភិបាល ។<br>● ការអនុវត្តន៍ក្រមសីលធម៌មិនគ្រប់គ្រាន់ ដែលជាហេតុនាំឱ្យកើតមានរឿងក្តីមានឥទ្ធិពលពីខាងក្រៅផ្សេងៗ ។<br>● ធនធានសម្រាប់នគរបាលយុត្តិធម៌មិនគ្រប់គ្រាន់ ឬតុលាការខ្វះធនធានសម្រាប់អនុវត្តការស៊ើបអង្កេតឱ្យបានគ្រប់ជ្រុងជ្រោយ ។<br>● បញ្ហាយឺតយ៉ាវនៃការបញ្ជូនដីកា និងសេចក្តីជូនដំណឹងផ្សេងៗពីតុលាការ ។ | ក្រៅប្រព័ន្ធតុលាការ គួរត្រូវបានរៀបចំឱ្យមានឡើង ។<br>● យន្តការនៃការសម្របសម្រួលរវាងភ្នាក់ងារអនុវត្ត និងអង្គការក្រៅរដ្ឋាភិបាលគួរត្រូវបានរៀបចំបង្កើតឡើង ។ គួរមានថវិកាសម្រាប់ការពិគ្រោះយោបល់ជាប្រចាំជាមួយអ្នកពាក់ព័ន្ធទាំងឡាយឱ្យបានទូលំទូលាយ ។<br>● សុំឱ្យមានធនធានគ្រប់គ្រាន់សម្រាប់ការស៊ើបអង្កេត ហើយចៅក្រមស៊ើបសួរគួរមានតួនាទីកាន់តែធំ ក្នុងការសួរចម្លើយ ។<br>● ប្រាក់ពន្ធក្នុងរឿងព្រហ្មទណ្ឌគួរតែដកចេញ<br>● ការបង់ប្រាក់ទាំងអស់គួរមានវិក័យប័ត្រ ។<br>● គួរមានជំនួយផ្នែកច្បាប់សម្រាប់អ្នកក្រីក្រ<br>● គួរមានវិធានការដើម្បីដោះស្រាយរឿងក្តីឱ្យបានកាន់តែឆាប់រហ័ស ។ |
| **តុលាការ និងអយ្យការ**<br>**បញ្ហាប្រឈម**<br>● ធនធាន និងថវិកាមិនគ្រប់គ្រាន់សម្រាប់ដំណើរការ និងការស៊ើបអង្កេតរបស់តុលាការ ។<br>● ខ្វះមេធាវី ក្រឡាបញ្ជី និងអ្នកជំនាញដែលពាក់ព័ន្ធ ។<br>● មានការលំបាកក្នុងការអនុវត្តសេចក្តីសម្រេច ។<br>● ខ្វះការសហការរវាងស្ថាប័ននានា ។<br>● ប្រជាពលរដ្ឋយល់ដឹងអំពីច្បាប់ និងនីតិវិធីនៅ | <br>**អនុសាសន៍:**<br>● សំណូមពរបង្កើនធនធាន ទាំងធនធានមនុស្ស និងសម្ភារៈ ដោយរួមទាំងថវិកាគ្រប់គ្រាន់សម្រាប់ដំណើរការ ។<br>● សុំបន្ថែមមេធាវី និងអ្នកជំនាញដែលពាក់ព័ន្ធ ។<br>● លក្ខន្តិកៈសម្រាប់ចៅក្រម ព្រះរាជអាជ្ញា និងក្រឡាបញ្ជីគួរចេញឱ្យបានឆាប់ ។<br>● សំណូមពរឱ្យមានរូបមន្តតុលាការ និង |

| | |
|---|---|
| មានកំរិត ។<br>● អន្តរាគមន៍ដែលនាំឱ្យប៉ះពាល់ដល់ឯករាជភាពរបស់តុលាការ កើតឡើងទាំងពេលជម្រះ និងពេលអនុវត្តសេចក្តីសម្រេច ។<br>● ភស្តុតាងមិនគ្រប់គ្រាន់ ដោយខ្វះជំនាញកោសលវិច័យ និងឧបករណ៍ ព្រមទាំងសាក្សីមានការស្ទាក់ស្ទើរក្នុងការចូលរួម ។<br>● កង្វះរូបមន្ត និងឯកសារផ្សេងៗ ។<br>● តុលាការស្ថិតនៅឆ្ងាយពីកន្លែងកើតហេតុ ដែលធ្វើឱ្យការស៊ើបអង្កេត ការបញ្ជូនសេចក្តីជូនដំណឹង និងការតាមដានត្រួតពិនិត្យការអនុវត្តសេចក្តីសម្រេចមានការលំបាក ។ | ឯកសារទាំងឡាយដែលប្រើបានសម្រាប់តុលាការទាំងអស់ទូទាំងប្រទេស ។<br>● សុំឱ្យមានការរៀបចំកន្លែងស្នាក់នៅសម្រាប់ចៅក្រម និងព្រះរាជអាជ្ញាដែលត្រូវបានផ្ទេរពីតុលាការមួយទៅតុលាការមួយទៀត ។<br>● សុំឱ្យមានការអនុវត្តន៍ក្រមសីលធម៌ ។<br>● សុំឱ្យមានការទំនាក់ទំនងឱ្យបានកាន់តែប្រសើរឡើងថែមទៀតរវាងស្ថាប័នពាក់ព័ន្ធទាំងឡាយ ។ |

## ឧបសម្ព័ន្ធទី២: មតិយោបល់របស់សិក្ខាកាម

សិក្ខាកាមម្នាក់ៗត្រូវបានស្នើសុំឱ្យបំពេញទម្រង់នៃការផ្តល់មតិ អំពីការយល់ឃើញរបស់គេ ព្រមទាំងសំណូមពរនានាដែលគេមាន:




